**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរ អាគារ ចលនទ្រព្យ អចលនទ្រព្យ និង ឯកសារពាក់ពន្ធ័ រវាង អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុវជន ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

## សំរេច

**មាត្រា១ :** ត្រូវបានផ្ទេរអាគារ ព្រមទាំងចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ពន្ធ័ របស់អគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រែកព្នៅ មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញ

កម្ពុជា-ថៃ (ពូនភ្នំ ) នៃអតីតក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អោយមក ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា២ :** ត្រូវបានផ្ទេរអគារ ព្រមទាំងចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ពន្ធ័របស់នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា៣ :** ត្រូវបានផ្ទេរចលនទ្រព្យ និងឯកសារពាក់ព័ន្ធរបស់នាយកដ្ឋានសោធនអតីតយុទ្ធជន នាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន មជ្ឈមណ្ឌលព្យាបាលដោយចលនា និងមន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត-ក្រុង ដែលសំរាប់ប្រើប្រាស់ក្នុងការងារវិស័យ អតីតយុទ្ធជន នៃអតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន អោយមកស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤

ទីស្តីការគណៈរដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចំលងជូនៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ